# សេចក្តីប្រកាសព័ត៌មានរួមស្តីពីកិច្ចប្រជុំពិសេសដែលរៀបចំដោយប្រទេសម៉ាឡេស៊ី ដើម្បីដោះស្រាយស្ថានការណ៍បច្ចុប្បន្នរវាងប្រទេសកម្ពុជា និងប្រទេសថៃ

រដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី កម្ពុជា និងថៃ ចេញសេចក្តីប្រកាសព័ត៌មានរួមនេះបន្ទាប់ពីកិច្ចប្រជុំពិសេស នៅទីក្រុងពូត្រាយៃយ៉ា ប្រទេសម៉ាឡេស៊ី ដែលឯកឧត្តម Dato' Seri Anwar Ibrahim នាយករដ្ឋមន្ត្រីម៉ាឡេស៊ី ក្នុងនាមជាម្ចាស់ផ្ទះ បានដឹកនាំ និងធ្វើជាសាក្សី និងមានការចូលរួមពី**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម Phumtham Wechayachai នាយករដ្ឋមន្ត្រីស្តីទីប្រទេសថៃ និងត្រូវបានសហការរៀបចំដោយសហរដ្ឋអាមេរិក ដោយមានការចូលរួមយ៉ាងសកម្មពីសាធារណរដ្ឋប្រជាមានិតចិន ដើម្បីជំរុញដំណោះស្រាយដោយសន្តិវិធីចំពោះស្ថានការណ៍ដែលកំពុងកើតឡើង។

សម្តេច ហ៊ុន ម៉ាណែត និងនាយករដ្ឋមន្ត្រីស្តីទី Phumtham Wechayachai បានលើកអំពីជំហររបស់ខ្លួន ព្រមទាំងឆន្ទៈសម្រាប់ការឈប់បាញ់ជាបន្ទាន់ និងការវិលត្រឡប់ទៅរកភាពប្រក្រតីឡើងវិញ។

ឯកឧត្តម Donald J. Trump ប្រធានាធិបតីសហរដ្ឋអាមេរិក បានទាក់ទងជាមួយមេដឹកនាំនៃប្រទេសទាំងពីរ ដើម្បីជំរុញការស្វែងរកដំណោះស្រាយដោយសន្តិវិធីចំពោះស្ថានការណ៍កំពុងកើតឡើង។

ភាគីចិនក៏បានរក្សាទំនាក់ទំនងជិតស្និទ្ធជាមួយកម្ពុជា ថៃ ម៉ាឡេស៊ី និងប្រទេសពាក់ព័ន្ធ ដើម្បីជំរុញយ៉ាងសកម្មឲ្យមានការសន្ទនាលើបទឈប់បាញ់ និងការស្តារសន្តិភាពឡើងវិញ។

វត្តមាន និងកិច្ចសហការរបស់ភាគីទាំងអស់ គូសបញ្ជាក់ពីការប្តេជ្ញាចិត្តរួមគ្នាចំពោះសន្តិភាព ការសន្ទនា និងស្ថិរភាពក្នុងតំបន់។

ភាគីកម្ពុជា និងថៃបានឈានដល់ការយោគយល់គ្នាដូចតទៅ៖

i. បទឈប់បាញ់ជាបន្ទាន់ និងគ្មានលក្ខខណ្ឌ ដែលមានប្រសិទ្ធភាពចាប់ពីម៉ោង២៤ (ម៉ោងក្នុងតំបន់) នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥។ នេះគឺជាជំហានដំបូងដ៏សំខាន់មួយឆ្ពោះទៅរកការកាត់បន្ថយអរិភាព និងការស្តារឡើងវិញនូវសន្តិភាព និងសន្តិសុខ;

ii. រៀបចំកិច្ចប្រជុំក្រៅផ្លូវការនៃមេបញ្ជាការភូមិភាគ (យោធភូមិភាគទី១ និងទី២ ខាងថៃ និងយោធភូមិភាគទី៤ និងទី៥ ខាងកម្ពុជា) នៅវេលាម៉ោង ០៧:០០នាទី ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ២០២៥ ហើយជាបន្តមកទៀត ប្រសិនបើភាគីទាំងពីរឯកភាពនឹងមានការជួបជាមួយក្រុមអនុព័ន្ធយោធានៃប្រទេសនានា ដឹកនាំដោយប្រធានអាស៊ាន និង

iii. កោះប្រជុំគណៈកម្មាធិការកិច្ចការព្រំដែនទូទៅ (GBC) នៅថ្ងៃទី ៤ ខែសីហា ឆ្នាំ២០២៥ ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ។

ក្នុងនាមជាប្រធានអាស៊ានបច្ចុប្បន្ន ម៉ាឡេស៊ីត្រៀមខ្លួនជាស្រេចក្នុងការសម្របសម្រួលក្រុមសង្កេតការណ៍ ដើម្បីផ្ទៀងផ្ទាត់ និងធានាការអនុវត្តបទឈប់បាញ់ ។ ម៉ាឡេស៊ីក៏នឹងពិគ្រោះយោបល់ផងដែរជាមួយប្រទេសសមាជិកអាស៊ាន ដើម្បីចូលរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងសង្កេតការណ៍ ដែលឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តក្នុងកម្រិតតំបន់លើការគាំទ្រដល់សន្តិភាពនៅលើដីជាក់ស្តែង។

ភាគីទាំងពីរក៏បានយល់ព្រមផងដែរ ក្នុងការបន្តឡើងវិញនូវទំនាក់ទំនងដោយផ្ទាល់រវាងនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងរដ្ឋមន្ត្រីការពារជាតិនៃប្រទេសទាំងពីរ។

រដ្ឋមន្ត្រីការបរទេស និងរដ្ឋមន្ត្រីការពារជាតិនៃប្រទេសម៉ាឡេស៊ី កម្ពុជា និងថៃ ត្រូវបានណែនាំឱ្យបង្កើតយន្តការលម្អិតសម្រាប់ការអនុវត្ត ផ្ទៀងផ្ទាត់ និងរាយការណ៍អំពីបទឈប់បាញ់។ យន្តការនេះនឹងដើរតួជាគ្រឹះ ដើម្បីសន្តិភាព និងការទទួលខុសត្រូវដោយចីរភាព។

អង្គប្រជុំបានបញ្ជាក់ឡើងវិញអំពីការប្តេជ្ញាចិត្តរួមរបស់ប្រទេសម៉ាឡេស៊ី កម្ពុជា និងថៃ ក្នុងការប្រកាន់ខ្ជាប់នូវគោលការណ៍ច្បាប់អន្តរជាតិ ការរួមរស់ជាមួយគ្នាដោយសន្តិភាព និងកិច្ចសហប្រតិបត្តិការពហុភាគី ក្នុងការស្វែងរកដំណោះស្រាយដ៏យុត្តិធម៌ និងយូរអង្វែងចំពោះស្ថានការណ៍។

ក្រុងពូត្រាយ៉ៃយ៉ា ថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០២៥